# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍*

ភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩

ដៃគូអភិវឌ្ឍន៍៖ មានតំណាងចំនួន ២៥រូប ចូលរួមមកពីស្ថាប័នដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគី ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា។

សេចក្តីផ្តើម៖ ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើការរៀបរាប់សង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្តោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលស្របតាមអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្តាវិស័យត្រូវផ្តោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្តីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានគ្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។ នៅក្នុងកិច្ចពិគ្រោះយោបល់នេះ អ្នកចូលរួមត្រូវបានបែងចែកជាក្រុមៗឱ្យធ្វើការជជែកបំផុសគំនិត កត់ត្រាចម្លើយតបទៅនឹងសំណួរពិភាក្សារបស់ធនាគារពិភពលោក ហើយបន្ទាប់មកធ្វើបទបង្ហាញអំពីការសន្និដ្ឋានតាមក្រុមរៀងៗខ្លួន។

បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាមាន៖ ការគាំពារសង្គម បរិស្ថាន កសិកម្ម គណនេយ្យភាព/អភិបាលកិច្ច

| វិស័យដែលត្រូវបានលើកយកមកពិភាក្សា | ចំណុចគោលសំខាន់ៗដែលបានលើកឡើង |
|---|---|

| | |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហាប្រឈមនិងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា?** | ▪ កង្វះប្រព័ន្ធគាំពារសង្គម និងភាពងាយរងគ្រោះរបស់ប្រជាជនចំពោះមុខវិបត្តិ គឺជាផ្នែកសំខាន់សម្រាប់ការអភិវឌ្ឍ ដែលដៃគូអភិវឌ្ឍន៍ជាច្រើនមានចំណាប់អារម្មណ៍ចូលរួមពាក់ព័ន្ធ។<br>▪ ការកើនឡើងបំណុល និងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច៖ វាមិនទាន់ដល់កម្រិតយ៉ាប់យ៉ឺនខ្លាំងទេ ប៉ុន្តែវាមានប្រយោជន៍ដែរក្នុងការពិនិត្យ និងធ្វើការគាំទ្រដល់សមត្ថភាព និងផែនការយុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈ។<br>▪ បំណុលគ្រួសារ និងការធ្វើចំណាកស្រុក គឺជាបញ្ហាប្រទាក់ក្រឡាគ្នាទៅវិញទៅមក - ទិន្នន័យបែបបរិមាណអាចនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយទេ ប៉ុន្តែបើនិយាយពីជ្រុងទិដ្ឋភាពបែបគុណភាពវិញ បញ្ហាទាំងនេះត្រូវបានគេដឹងឮយ៉ាងច្បាស់ហើយ។ ការធ្វើចំណាកស្រុកនៅក្នុងប្រទេស និងសកម្មភាពនគរូបនីយកម្ម ក៏ជាបញ្ហាប្រឈមសម្រាប់ទីក្រុងនានារបស់ប្រទេសកម្ពុជា ក៏ដូចជាធនធានមនុស្សដែលមាននៅក្នុងតំបន់ជនបទដែរ។<br>▪ គណនេយ្យភាព/តម្លាភាព នៅតែជាបញ្ហាអន្តរវិស័យ។<br>▪ បញ្ហាបរិស្ថានកំពុងតែធ្វើឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងឡើង ក៏ដូចជាភាពងាយរងគ្រោះរបស់ប្រជាជនចំពោះគ្រោះមហន្តរាយធម្មជាតិ ផងដែរ។<br>▪ ការធ្វើពិពិធកម្មកសិកម្មគឺជាបញ្ហាសំខាន់មួយទៀត ដោយសារផលិតផលកសិកម្មរបស់កម្ពុជាជួបប្រទះការលំបាកក្នុងការប្រកួតប្រជែងជាមួយនឹងប្រទេសជិតខាង។ |
| **តើមានអ្វីខ្លះជាវិស័យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភព** | *ការអភិវឌ្ឍមនុស្ស*<br>• ការគាំពារសង្គមគឺជាវិស័យគន្លឹះមួយដែលត្រូវការអភិវឌ្ឍន៍បន្ថែម ហើយដែលធនាគារពិភពលោកហាក់ដូចជាមានជំហររឹងមាំក្នុងការចូលពាក់ព័ន្ធ ដោយផ្អែកលើបទពិសោធន៍អន្តរជាតិរបស់ខ្លួន។ តើមានច្រកបើកចំហណាមួយសម្រាប់ឱ្យធនាគារពិភពលោកចូលរួមក្នុងវិស័យនេះបានដែរឬទេ? (ឧ. ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ)<br>• ដៃគូអភិវឌ្ឍន៍ដទៃទៀតក៏បានធ្វើការកត់សម្គាល់ផងដែរថា ការគាំពារសង្គមគឺជាឈ្នាន់បង្កើនល្បឿនសម្រាប់ការអភិវឌ្ឍ ដូច្នេះវាអាចជាផ្នែកមួយសម្រាប់កិច្ចសហប្រតិបត្តិការគ្នានាពេលអនាគត។ ដៃគូអភិវឌ្ឍន៍ជាច្រើនចង់ភ្ជាប់កិច្ចគាំពារសង្គមឱ្យបានកាន់តែល្អប្រសើរឡើងជាមួយមូលធនមនុស្ស កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយហានិភ័យផ្នែកសេដ្ឋកិច្ច ដើម្បីធ្វើឱ្យប្រធានបទនេះកាន់តែមានទំនាក់ទំនងគ្នាឡើង។<br>• បញ្ហាអាហារូបត្ថម្ភ និងយុវជន នៅតែជាវិស័យអភិវឌ្ឍន៍មនុស្សដ៏សំខាន់សម្រាប់ការគាំទ្ររបស់ធនាគារពិភពលោក ហើយវាផ្តល់ឱកាសឱ្យមានការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការគ្នាក្នុងចំណោមដៃគូអភិវឌ្ឍន៍។ |

| | |
|---|---|
| **លោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយសកម្មភាពវិញ?** | *អភិបាលកិច្ច*<br>• ធនាគារពិភពលោកមានបទពិសោធល្អៗលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព ជាពិសេស ទាក់ទងជាមួយនឹងលទ្ធកម្ម និងតម្លាភាព ដូច្នេះត្រង់នេះអាចជាផ្នែកមួយមានឧត្តមភាពដែលអាចប្រៀបធៀបបាន។<br>• អភិបាលកិច្ចដែលទាក់ទងទៅនឹងឱកាសសម្រាប់នវានុវត្តន៍(ការច្នៃប្រឌិត) និងសេដ្ឋកិច្ចឌីជីថល គឺជាផ្នែកមួយល្អគួរធ្វើការពិនិត្យសិក្សាមើលលទ្ធភាពដែរ។ សេដ្ឋកិច្ចឌីជីថលនឹងក្លាយជាផ្នែកមួយដែលមានការចាប់អារម្មណ៍ និងជាអាទិភាពនាពេលខាងមុខ សម្រាប់សក្តានុពលការគាំទ្ររបស់ធនាគារពិភពលោក ក៏ដូចជា PPPs ដែរ។ រដ្ឋាភិបាលមានចំណាប់អារម្មណ៍ក្នុងការទាញវិស័យឯកជនឱ្យចូលពាក់ព័ន្ធនៅក្នុងផ្នែកនេះ នៅពេលណាក៏បានដែរ តាមតែអាចធ្វើទៅបាន។<br><br>*បរិស្ថាន និងកសិកម្ម*<br>• ការគ្រប់គ្រង ធនធានទឹកមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជាក្នុងនាមជាប្រទេសមួយនៅចុងខ្សែទឹក។ មានការកត់សម្គាល់ឃើញថាធនាគារពិភពលោក នៅតែបន្តចូលពាក់ព័ន្ធតាមរយៈការងារគ្រប់គ្រងចម្រុះលើធនធានទឹកទន្លេមេគង្គ និងក៏ដូចក្នុងការងារបរិស្ថានដែរ។ វានឹងមានប្រយោជន៍ដែរនៅក្នុងការពិនិត្យមើលចំណុចនេះពីជ្រុងទស្សនៈវិស័យក្នុងតំបន់ និងអភិបាលកិច្ច។<br>• ដៃគូអភិវឌ្ឍន៍ចង់ស្វែងយល់ពីការថាតើ ធនាគាពិភពលោក បញ្ចូលបញ្ហាយេនឌ័រទៅក្នុងការងាររបស់ខ្លួនដូចម្តេចខ្លះ ពីព្រោះថានេះជាបញ្ហាមានលក្ខណៈអន្តរវិស័យ ដែលត្រូវបានរកឃើញដោយតួអង្គជាច្រើននៅក្នុងការងារអភិវឌ្ឍន៍។<br>• ការគ្រប់គ្រងធនធានធម្មជាតិអាចមានតំណភ្ជាប់ជាមួយនឹងការអភិវឌ្ឍសហគមន៍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដោយសារថាគេឃើញនៅមានឱកាសអេកូទេសចរណ៍ល្អច្រើននោះឡើយ ដែលអាចភ្ជាប់ទៅនឹងការការពារបរិស្ថាន បានដែរ។ ធនាគារពិភពលោកបានកត់សម្គាល់ថា ការគាំទ្រអេកូទេសចរណ៍នឹងមកដល់តាមរយៈគម្រោងនាពេលខាងមុខ។<br>• វិស័យកសិកម្មត្រូវបានកំណត់ថាជាវិស័យអាទិភាពសម្រាប់ផ្តល់ការគាំទ្រ ដូច្នេះអ្នកចូលរួមជាច្រើនមានការពេញចិត្តក្នុងការមើលឃើញថាការគាំទ្រនឹងមានមកដល់នៅពេលខាងមុខ។ មានដៃគូជាច្រើនធ្វើការនៅក្នុងវិស័យនេះ ដែលជួនកាលនាំឱ្យមានវិធីសាស្ត្រមួយជាលក្ខណៈរដាច់រដោច ខ្វះភាពទៀងទាត់ទៅវិញ។ |
| **តើមានអ្វីខ្លះដែលអាចជាបញ្ហាប្រឈមគួរឱ្យកត់** | • យន្តការសម្របសម្រួលតាមវិស័យដែលមានស្រាប់មិនមែនតែងតែមានប្រសិទ្ធភាពទេ។ ដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវការធ្វើការឱ្យបានជិតស្និទ្ធជាមួយគ្នា ដើម្បីចៀសវាងការធ្វើការដោយឡែកៗ។<br>• សមត្ថភាពរបស់ទីភាក់ងាររដ្ឋបាលសាធារណៈ ឬការបែងចែកការទទួលខុសត្រូវតាមវិស័យរវាងស្ថាប័នផ្សេងៗគ្នាអាចបង្កបញ្ហាប្រឈមដល់ |

| | |
|---|---|
| **សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបានកាត់បន្ថយតាមរបៀបណាខ្លះ ?** | ការអនុវត្តគម្រោង។<br>• ដៃគូអភិវឌ្ឍន៍ដទៃទៀតក៏ប្រឈមនឹងបញ្ហាចំណាយផងដែរ។ វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់បញ្ហារាំងស្ទះ និងប្រើវិធីទាំងនេះដើម្បីដឹកនាំយុទ្ធសាស្ត្រនាពេលអនាគត។ |
| **អត្ថាធិប្បាយផ្សេងៗទៀត** | • អ្នកចូលរួមក្នុងការពិគ្រោះយោបល់បានសម្តែងនូវការកោតសរសើរចំពោះការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) របស់ធនាគារពិភពលោក។ ដៃគូអភិវឌ្ឍន៍ភាគច្រើនបានលើកឡើងថាពួកគេស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍យុទ្ធសាស្ត្រចូលរួមពាក់ព័ន្ធសម្រាប់ប្រទេសរបស់ខ្លួនដែរ ហើយអ្នកចូលរួមជាច្រើនបាននិយាយថា មានការសម្របតម្រឹម និងភាពត្រួតស៊ីគ្នាគួរឱ្យកត់សម្គាល់ច្រើន នៅក្នុងការរកឃើញរបស់ពួកគេ និងសសរស្តម្ភមានសក្តានុពលសម្រាប់ការចូលរួមពាក់ព័ន្ធ ជាពិសេសនៅក្នុងការអភិវឌ្ឍមនុស្ស។ ដៃគូអភិវឌ្ឍន៍មួយចំនួនបាននិយាយថាពួកគេនឹងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើកំណើនបៃតង និងបរិស្ថាន ក៏ដូចជាការប្រកួតប្រជែងផងដែរ។<br>• ដៃគូអភិវឌ្ឍន៍បានពិភាក្សាអំពីភាពចាំបាច់ក្នុងការប្រៀបធៀប និងចែករំលែកផែនការយុទ្ធសាស្ត្រដែលកំពុងដំណើរការ និងមាននៅថ្ងៃខាងមុខដើម្បីជានាយ៉ាងណាកុំឱ្យការងារអភិវឌ្ឍន៍មានលក្ខណៈដាច់ពីគ្នាជាដុំៗ និងគួរតែមានការសហការនៅពេលណាដែលអាចធ្វើទៅបាន។<br>• ដៃគូអភិវឌ្ឍន៍ចង់ពិភាក្សាអំពីភាពប្រទាក់ប្រទងគ្នារវាងយុទ្ធសាស្ត្រនានារបស់ប្រទេសកម្ពុជាជាមួយ SDGs ក៏ដូចជាថាតើទីភ្នាក់ងារផ្សេងៗលៃលកដូចម្តេចជាមួយបញ្ហាអន្តរវិស័យ។<br>• ទីតាំងរបស់កម្ពុជានៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសមាហរណកម្មក្នុងតំបន់ គឺជាវិស័យមួយទៀតសម្រាប់ការពិភាក្សាក្នុងចំណោមដៃគូអភិវឌ្ឍន៍នាពេលអនាគត។ |